ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០១៥ MIH / ២០១៧

# ប្រកាស

## ស្តីពី

## ការបង្កើតការិយាល័យច្រកចេញ ចូលតែមួយ នៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់ នៃអគ្គនាយកដ្ឋានឧស្សាហកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសរួម ៧១៧សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យ អន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ ៖** បង្កើតការិយាល័យច្រកចេញ ចូលតែមួយ នៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់ (Department of Accredittaion) នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីសម្រប សម្រួល និងបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម អង្គភាពវាយតម្លៃភាពអនុលោម (Conformity Assessment Bodies) នៅក្រោមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com

**ប្រការ២** ៖ ចាត់តាំងមន្ត្រីការិយាល័យច្រកចេញ ចូលតែមួយ នៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់មាន៖

១-លោក **ម៉ៅ ព្រហស្បត្តិ៍** ប្រធានការិយាល័យ និងជារដ្ឋទេយ្យករចំណាយរង ប្រធាន

២-អ្នកស្រី **ភាព កន្និកា** មន្ត្រីនាយកដ្ឋានវាយតម្លៃទទួលស្គាល់ និងជារដ្ឋទេយ្យករចំណូលរង អនុប្រធាន

**ប្រការ៣** ៖ ត្រូវចាត់តាំងមន្ត្រីប្រចាំការនៅជួរមុខ ការិយាល័យច្រកចេញ ចូលតែមួយនៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់ សម្រាប់ទទួលពាក្យចូលមាន៖

១- លោក **យ៉ូត វិចិត្រ** មន្ត្រីនាយកដ្ឋានវាយតម្លៃទទួលស្គាល់ សមាជិក

២- កញ្ញា **ស៊ីន ម៉ានិច្ច** មន្ត្រីនាយកដ្ឋានវាយតម្លៃទទួលស្គាល់ សមាជិក

**ប្រការ៤** ៖ ត្រូវចាត់តាំងមន្ត្រីប្រចាំការនៅជួរក្រោយ ការិយាល័យច្រកចេញ ចូលតែមួយ នៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់មាន៖

១-លោក **ឥន្ទ ដារ៉ា** អនុប្រធានការិយាល័យ សមាជិក

២-លោក **សួរ គុជ្យសៀក** មន្ត្រីនាយកដ្ឋានវាយតម្លៃទទួលស្គាល់ សមាជិក

៣-លោក **លឹម ហុង** មន្ត្រីនាយកដ្ឋានវាយតម្លៃទទួលស្គាល់ សមាជិក

**ប្រការ៥** ៖ ការិយាល័យច្រកចេញ ចូលតែមួយមានភារកិច្ច ៖

- ទទួល និងពិនិត្យឯកសារស្នើសុំ រួចបញ្ជូនទៅតាមការិយាល័យជំនាញ ដើម្បីអនុវត្តតាមបែបបទ និងនីតិវិធីនៃប្រព័ន្ធគ្រប់គ្រងការងារវាយតម្លៃទទួលស្គាល់
- ពិនិត្យឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ រួចចេញជា Quotation ប៉ាន់ស្មានជូនអតិថិជន ឬលិខិតអនុញ្ញាត បង់ប្រាក់ជូនអតិថិជន ទៅបង់ប្រាក់នៅបញ្ជរបង់ប្រាក់ដែលស្ថិតនៅក្នុងទីតាំងច្រកចេញ ចូលតែមួយ
- ពិនិត្យ ទទួលសាច់ប្រាក់ រួចចេញបង្កាន់ដៃបង់ប្រាក់ជូនអតិថិជន
- គ្រប់គ្រងការចុះបញ្ជីការចូល-ចេញ ក្នុងការទទួលឯកសារ និងរៀបចំប្រគល់ឯកសារសម្រេចចុងក្រោយជូនអតិថិជនតាមប្រព័ន្ធគ្រប់គ្រងវាយតម្លៃទទួលស្គាល់
- ដំណើរការផ្តល់សេវា ដោយតម្លាភាព និងគណនេយ្យភាព តាមគោលការណ៍ច្រកចេញ ចូលតែមួយ និងប្រព័ន្ធវាយតម្លៃទទួលស្គាល់ អនុលោមស្តង់ដារអន្តរជាតិ ISO/IEC 17011
- ទទួលពាក្យតវ៉ា និងបណ្តឹងតវ៉ា (Complaint and Appeal) ពីអតិថិជនលើការងារផ្តល់សេវាដោយនាយកដ្ឋានវាយតម្លៃទទួលស្គាល់ និងការផ្តល់សេវាពីអង្គភាពវាយតម្លៃភាពអនុលោម Conformity Assessment Bodies (CABs)
- ធ្វើរបាយការណ៍បូកសរុបចំណូលសេវាសាធារណៈ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំនាយកដ្ឋានវាយតម្លៃទទួលស្គាល់ អគ្គនាយកដ្ឋានកិច្ចការទូទៅ ក្រុមប្រឹក្សាជាតិវាយតម្លៃ- ទទួលស្គាល់ (CANC) និង PAC, APLAC, IAF, ILAC.
- បំពេញភារកិច្ចដទៃទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួង។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com

**<u>ប្រការ៦</u>** ៖ ត្រូវបានចាត់តាំងមន្ត្រីប្រចាំការផ្នែកទទួលពាក្យបណ្ដឹង និងត្រួតពិនិត្យ នៃការិយាល័យប្រកចេញ ចូលតែ មួយនៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ចំនួន០១នាក់។

**<u>ប្រការ៧</u>** ៖ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**<u>ប្រការ៨</u>**៖ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u>** ៖

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អង្គភាពប្រឆាំងអំពើពុករលួយ

*« ដើម្បីជូនជ្រាប »*

- ដូចប្រការ៨

*« ដើម្បីអនុវត្ត »*

- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com